## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**

-លេខ ៥១០ "ម" ក្រ.៦

ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៩។

-សំណុំរឿងព្រហ្មទណ្ឌលេខ ១១៣៦

ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៩។

-សំណុំរឿងស៊ើបសួរលេខ៥៨៦

ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩។

-សំណុំរឿងជំនុំជម្រះលេខ១៦៩៧

ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៩។

### តាងនាមប្រជារាស្ត្រខ្មែរ
### សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ ២០១៩ វេលាម៉ោង ០២ និង ៣០ នាទី រសៀល នៅសាលសវនាការទី៥ ដោយមានសមាសភាព ៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធានក្រុមប្រឹក្សា

លោក [redacted] ចៅក្រមក្រុមប្រឹក្សា

លោកស្រី [redacted] ចៅក្រមក្រុមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១១៣៦ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៩ ដែលមានជនជាប់ចោទ៖

១. ឈ្មោះ [redacted] រិទ្ធី ភេទប្រុស អាយុ ២០ឆ្នាំ ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើតនៅភូមិ [redacted] រាជធានីភ្នំពេញ ទីលំនៅសព្វថ្ងៃនៅភូ[redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] សំអឿន "រ" ម្តាយឈ្មោះ [redacted] សាបុង "រ" នៅលីវ ជានីតិជន ទោសពីមុនគ្មាន។

. ដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នលេខ ១០១៨ "ខ១"ង.ព.ស ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ ។

. ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៥៧៦"ខ១" ង.ឃ.ង ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩។

២. ឈ្មោះ [redacted] វុទ្ធី ហៅ ធី ភេទប្រុស អាយុ ១៨ ឆ្នាំ ជនជាតិខ្មែរ មុខរបរ ចិតផ្ទៃឈើក្នុងហាង ទីកន្លែងកំណើតនៅភូមិ[redacted] រាជធានីភ្នំពេញទីលំនៅសព្វថ្ងៃនៅ[redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] តែក "រ" ម្តាយឈ្មោះ [redacted] ហ៊ាន់ "រ" នៅលីវ ជានីតិជន ទោសពីមុនគ្មាន ។

. ដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នលេខ ១០២១ "ខ១"ង.ព.ស ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ ។

. ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៥៧៩"ខ១" ង.ឃ.ង ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩។

៣. ឈ្មោះ [redacted] វណ្ណនៈ ហៅ លី ភេទប្រុស អាយុ ២១ ឆ្នាំ ជនជាតិខ្មែរ មុខរបរ រត់តុការ ទីកន្លែងកំណើតនៅភូមិ [redacted] រាជធានីភ្នំពេញ ទីលំនៅសព្វថ្ងៃនៅភូ[redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted] បុណ្យ "រ" ម្តាយឈ្មោះ[redacted] សុជាតិ "រ" នៅលីវ ជានីតិជន ទោសពីមុនគ្មាន។



Scanned with CamScanner

- ដីកាសម្រេចឲ្យឃុំខ្លួនបណ្ដោះអាសន្នលេខ ១០១៦ "ខ១" ដ.ព.ស ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ ។
- ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៥៧៤"ខ១" ដ.ឃ.ដ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩។

៤. ឈ្មោះ[redacted] ឧត្តម ភេទប្រុស អាយុ ១៨ឆ្នាំ ជនជាតិខ្មែរ មុខរបរ សិស្ស ទីកន្លែងកំណើតនៅ[redacted] ខេត្តកណ្ដាល ទីលំនៅសព្វថ្ងៃនៅភូមិ[redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted]វីរៈ "រ" ម្ដាយឈ្មោះ [redacted]សុគន្ធារី "រ" នៅលីវ ជាទីតិជន ទោសពីមុនគ្មាន ។

- ដីកាសម្រេចឲ្យឃុំខ្លួនបណ្ដោះអាសន្នលេខ ១០១៧"ខ១" ដ.ព.ស ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ ។
- ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៥៧៥"ខ១" ដ.ឃ.ដ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩។

៥. ឈ្មោះ[redacted]សុខឡេង ភេទប្រុស អាយុ ២៣ឆ្នាំ ជនជាតិខ្មែរ មុខរបរ ចុងភៅ ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តកណ្ដាល ទីលំនៅសព្វថ្ងៃនៅ សង្កាត់[redacted] ភ្នំពេញ ឪពុកឈ្មោះ [redacted] ឡា "រ" ម្ដាយឈ្មោះ[redacted] ម៉ៃ "រ" នៅលីវ ជាទីតិជន ទោសពីមុនគ្មាន ។

- ដីកាសម្រេចឲ្យឃុំខ្លួនបណ្ដោះអាសន្នលេខ ១០១៩ "ខ១" ដ.ព.ស ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ ។
- ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៥៧៧ "ខ១" ដ.ឃ.ដ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩។

ត្រូវបានចោទប្រកាន់ពីបទ លួចមានស្ថានទម្ងន់ទោស ដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចផ្លូវជាតិលេខ១ កែងផ្លូវលេខ៣៥១ ភូមិតាងៅ សង្កាត់និរោធ៍ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៩ តាមបញ្ញត្តិមាត្រា៣៥៣ មាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៦. ឈ្មោះ[redacted] រាជ ភេទប្រុស អាយុ ១៨ ឆ្នាំ ជនជាតិខ្មែរ មុខរបរ បុគ្គលិកភោជនីយដ្ឋាន ទីកន្លែងកំណើត [redacted] រាជធានីភ្នំពេញ ទីលំនៅសព្វថ្ងៃនៅភូ[redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ពីង "ស" ម្ដាយឈ្មោះ [redacted] លួន "ស" ប្រពន្ធឈ្មោះ [redacted] ស្រីណែត ជាទីតិជន ទោសពីមុនគ្មាន ។

- ដីកាសម្រេចឲ្យឃុំខ្លួនបណ្ដោះអាសន្នលេខ ១០២០ "ខ១" ដ.ព.ស ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ ។
- ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៥៧៨ "ខ១" ដ.ឃ.ដ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩។

ត្រូវបានចោទប្រកាន់ពីបទ ទទួលផលចោរកម្ម ប្រព្រឹត្តនៅចំណុចផ្លូវជាតិលេខ១ កែងផ្លូវលេខ៣៥១ ភូមិតាងៅ សង្កាត់និរោធ៍ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៩ តាមបញ្ញត្តិមាត្រា៣៩៩ និង មាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ។

- ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុផាន់ណា ភេទប្រុស អាយុ២០ ឆ្នាំ ទីលំនៅសព្វថ្ងៃនៅផ្ទះលេខ៦០៨ ផ្លូវជាតិលេខ១ សង្កាត់ច្បារអំពៅ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។
- ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សែនដារ័ត្ន ភេទប្រុស អាយុ២០ ឆ្នាំ ទីលំនៅសព្វថ្ងៃនៅផ្ទះលេខ០៨ ផ្លូវលំ សង្កាត់ច្បារអំពៅ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។
- លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទទាំងប្រាំមួយនាក់។



Scanned with CamScanner

## អង្គហេតុដែលត្រូវបានចោទប្រកាន់

កាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៩ ជនរងគ្រោះឈ្មោះ [redacted] សុផាន់ណា បានជិះម៉ូតូម៉ាក Honda Dream C125 សេរីឆ្នាំ២០១៨ ពាក់ស្លាកលេខភ្នំពេញ 1HA-3701 នៅចំណុចផ្លូវជាតិលេខ១ កែងផ្លូវលេខ៣៥១ ភូមិតាងៅ សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ស្រាប់តែមានជនសង្ស័យ ០៥ នាក់ មានឈ្មោះ [redacted] រិទ្ធ ឈ្មោះ [redacted] វុទ្ធី ឈ្មោះ [redacted] វឌ្ឍនៈ ឈ្មោះ [redacted] ឧត្តម និងឈ្មោះ [redacted] សុខឡេង ប្រដាប់ដោយដាវ និងខ្សែក្រវ៉ាត់បានរួមគ្នាធ្វើសកម្មភាពវាយប្លន់យកម៉ូតូរបស់ជនរងគ្រោះខាងលើបានសម្រេច ហើយក៏នាំគ្នាជិះម៉ូតូគេចខ្លួនបាត់អស់។ បន្ទាប់ពីប្លន់បានម៉ូតូខាងលើបានហើយជនសង្ស័យខាងលើ បានយកម៉ូតូទៅលក់ឱ្យឈ្មោះ [redacted] រាជ បានតម្លៃ ៥៥០ ដុល្លារអាមេរិក។ លុះមកដល់ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៩ សមត្ថកិច្ចក៏ធ្វើការស្រាវជ្រាវ ឈានដល់ការឃាត់ខ្លួនបានជនសង្ស័យទាំង ០៦ នាក់ខាងលើបានតែម្តង។

- បានឃើញពាក្យបណ្តឹងរបស់ឈ្មោះ ឆោម សុផាន់ណា ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៩។
- របាយការណ៍សំយោគលេខ ០១៦/១៩ រ.ប.ក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ការិយាល័យព្រហ្មទណ្ឌកម្រិតធ្ងន់ ។
- បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១១៣៦ អ.យ.ផ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។
- បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ១៤១២ អ.យ.ផ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។
- បានឃើញ ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ ១៨៩៣"ខ១" ដ.ដចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

## ដំណើរការ នៃកិច្ចពិភាក្សាដេញដោល

១. ជនជាប់ចោទឈ្មោះ [redacted] រិទ្ធ បានឆ្លើយនៅមុខតុលាការថា ៖ ខ្ញុំបាទសូមទទួលយកការចោទប្រកាន់របស់តំណាងអយ្យការ ដែលបានចោទខ្ញុំបាទពីបទលួច ដោយនៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៩ វេលាម៉ោង ប្រហែល ៨ យប់ ខ្ញុំកំពុងនៅផ្ទះ ហើយខលហៅមិត្តភក្តិខ្ញុំបាទឈ្មោះ [redacted] វុទ្ធី មកយកខ្ញុំបាទទៅដើរលេងកោះពេជ្រ ឈ្មោះ [redacted] វុទ្ធី បានជិះម៉ូតូម៉ាក និច មកយកខ្ញុំបាទជិះទៅដើរលេងកោះពេជ្រ។ ពេលទៅដល់ ខ្ញុំបាទបានជួប ឈ្មោះ [redacted] សុខឡេង ឈ្មោះ [redacted] វឌ្ឍនៈ ឈ្មោះ [redacted] ឧត្តម ឈ្មោះ [redacted] ឈ្មោះ ងាន់ ដែលកំពុងផឹកប៊ីយែរនៅ កោះពេជ្រ។ សរុបទាំងខ្ញុំបាទ និងឈ្មោះ [redacted] វុទ្ធី គឺមានគ្នា ០៧ នាក់។ លុះម៉ោងជិត ១០ យប់ ពួកខ្ញុំបាទបានចេញពីកោះពេជ្រមកផឹកស្រាឈុតនៅមុខណាហ្គា។ ពួកខ្ញុំបាទផឹករហូតដល់ម៉ោងប្រហែល ៣ភ្លឺ ក៏ឈប់ផឹកនាំគ្នាជិះម៉ូតូទៅផ្ទះវិញ។ ពេលជិះចេញមកវិញមានគ្នា៧នាក់ ជិះម៉ូតូ៤ដដែល។ លុះជិះមកដល់មុខក្រសួងមហាផ្ទៃ ស្រាប់តែជួបមនុស្សប្រុសបីនាក់ជិះម៉ូតូមួយគ្រឿង ដែលធ្លាប់មានជម្លោះជាមួយខ្ញុំបាទ ពួកខ្ញុំបាទក៏បាននាំគ្នា ដេញវាយពួកទាំងអស់នោះ។ ពេលនោះមានមនុស្សប្រុសបីនាក់ជិះម៉ូតូមួយគ្រឿងចូលកាវ៉ាស់សាំងតេលា ជាប់របងអគ្គស្នងការដ្ឋាននគរបាលជាតិ ផ្តួលម៉ូតូចោល ហើយរត់ចូលម៉ាតតេលា។ ពួកខ្ញុំមិនបានចូលវាយវាទេ។ ស្រាប់តែឈ្មោះ [redacted] វឌ្ឍនៈ ហៅ លីន ស្រែកថាមានគ្នាវាម្នាក់ជិះម៉ូតូម្នាក់ឯងរត់គេចខ្លួនទៅមុខ។ ឈ្មោះ [redacted] វឌ្ឍនៈ ហៅ លីន បានជិះម៉ូតូដោយមានឈ្មោះ វ៉ា សុខឡេង ជាអ្នកឌុបជិះដេញជនរងគ្រោះម្នាក់នោះទៅដល់មុខ វត្តនិរោធ។ ខ្ញុំបាទ និងឈ្មោះ [redacted] វុទ្ធី ឈ្មោះ [redacted] ឧត្តម ឈ្មោះ [redacted] ឈ្មោះ ងាន់ ក៏ជិះម៉ូតូបី គ្រឿងដេញតាមពីក្រោយ។ ពេលទៅដល់ជនរងគ្រោះបត់ម៉ូតូក៏រអិលដួលហើយឈ្មោះ [redacted] វឌ្ឍនៈ ហៅ លីន បានចុះទៅលើកម៉ូតូជនរងគ្រោះ



Scanned with CamScanner

យកម៉ូតូជនរងគ្រោះជិះត្រឡប់មកវិញមកតាមវត្តកំសាន្ត ហើយក៏បបួលគ្នាជិះដើរលេខនៅខេត្តកំពត ពួកខ្ញុំជិះទៅដល់ខេត្តកំពតនៅម៉ោងប្រហែល ៧ ភ្លឺ ថ្ងៃទី១៧ ខែមករា ឆ្នាំ ២០១៩។ ឈ្មោះ [redacted] វណ្ណនៈ ហៅ លីន បានខលសួរឈ្មោះ [redacted] រាជ ថាចង់ទិញម៉ូតូឬទេ។ ឈ្មោះ [redacted] រាជ ហើយឈ្មោះ [redacted] រាជ បានសួរថា ម៉ូតូរបស់អ្នកណា? ពេលនោះឈ្មោះ [redacted] វណ្ណនៈ ហៅ លីន ក៏បានប្រាប់ទៅវិញថា ម៉ូតូលួចគេមក ពេលនោះឈ្មោះ [redacted] រាជ ក៏បានទិញម៉ូតូនោះ ដោយផ្ញើរលុយចំនួន ៥៥០ ដុល្លារអាមេរិក ដោយផ្ញើរលុយតាមវីងមកឲ្យពួកខ្ញុំ។ ពួកខ្ញុំបានជិះម៉ូតូដើរលេងនៅខេត្តកំពត ដោយដេកបីយប់ ទើបត្រឡប់មកវិញ ដោយបែកគ្នានៅតាខ្មៅ នៅពេលដើរលេងនោះគឺចាយលុយលក់ម៉ូតូដែលពួកខ្ញុំលួចគេមកនោះ។ នៅពេលមកដល់តាខ្មៅ ឈ្មោះ [redacted] រាជ បាន មកយកម៉ូតូ។ លុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៩ ម៉ោងប្រហែល ០៨ ព្រឹក ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនខ្ញុំបាទតែម្តង។

២. ជនជាប់ចោទឈ្មោះ [redacted] ឧត្តម បានឆ្លើយនៅមុខតុលាការថា៖ ខ្ញុំបាទសូមសារភាពថា ខ្ញុំបាទពិតជាបានចូលរួមធ្វើសកម្មភាព លួចម៉ូតូរបស់ជនរងគ្រោះពិតប្រាកដមែន ដោយនៅថ្ងៃកើតហេតុខ្ញុំ រួមមួយបក្សពួក ០៧ នាក់ ទៀត ដោយមានឈ្មោះ [redacted] រិទ្ធ ឈ្មោះ រ៉ា សុខឡេង ឈ្មោះ [redacted] វណ្ណនៈ ឈ្មោះ [redacted] វុទ្ធី ឈ្មោះ [redacted] ឈ្មោះ ង៉ាន់ និងរូបខ្ញុំបាទ។ លុះជិះមកដល់មុខក្រសួងមហាផ្ទៃ ស្រាប់តែជួបមនុស្សប្រុស បីនាក់ជិះម៉ូតូមួយគ្រឿង ដែលធ្លាប់មានជម្លោះជាមួយឈ្មោះ [redacted] រិទ្ធ ពេលនោះពួកខ្ញុំបាទក៏បាននាំគ្នា ដេញវាយពួកទាំងអស់នោះ។ ស្រាប់តែឈ្មោះ [redacted] វណ្ណនៈ ហៅ លីន ស្រែកថាមានគ្នាវាម្នាក់ជិះម៉ូតូម្នាក់ឯងរត់គេចខ្លួនទៅមុខ។ ឈ្មោះ [redacted] វណ្ណនៈ ហៅ លីន បានជិះម៉ូតូដោយមានឈ្មោះ [redacted] សុខឡេង ជាអ្នកឌុបជិះដេញជនរងគ្រោះម្នាក់នោះទៅដល់មុខវត្តនិរោធ។ ពេលទៅដល់ជនរងគ្រោះបត់ម៉ូតូក៏រអិលដួលហើយឈ្មោះ [redacted] វណ្ណនៈ ហៅ លីន បានចុះទៅលើកម៉ូតូ ជនរងគ្រោះ យកម៉ូតូជនរងគ្រោះជិះត្រឡប់មកវិញមកតាមវត្តកំសាន្ត ហើយក៏បបួលគ្នាជិះ ដើរលេខនៅខេត្តកំពត ពួកខ្ញុំជិះទៅដល់ខេត្តកំពតនៅម៉ោងប្រហែល ៧ ភ្លឺ ថ្ងៃទី១៧ ខែមករា ឆ្នាំ ២០១៩។ ឈ្មោះ [redacted] វណ្ណនៈ ហៅ លីន បានខលសួរឈ្មោះ [redacted] រាជ ថាចង់ទិញម៉ូតូឬទេ។ ហើយឈ្មោះ [redacted] រាជ បានសួរថា ម៉ូតូរបស់អ្នកណា? ពេលនោះឈ្មោះ [redacted] វណ្ណនៈ ហៅ លីន ក៏បានប្រាប់ទៅវិញថា ម៉ូតូលួចគេមក ពេលនោះឈ្មោះ [redacted] រាជ ក៏បានទិញម៉ូតូនោះ ដោយផ្ញើរលុយចំនួន ៥៥០ ដុល្លារអាមេរិក ដោយផ្ញើរលុយតាមវីងមកឲ្យពួកខ្ញុំ។ ពួកខ្ញុំបានជិះម៉ូតូដើរលេងនៅខេត្តកំពត ដោយដេក បីយប់ ទើបត្រឡប់មក វិញ ដោយបែកគ្នានៅតាខ្មៅ នៅពេល ដើរលេងនោះគឺចាយលុយលក់ម៉ូតូដែលពួកខ្ញុំលួចគេមកនោះ។ នៅពេលមកដល់តាខ្មៅ ឈ្មោះ [redacted] រាជ បានមកយកម៉ូតូ។ លុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៩ ម៉ោងប្រហែល ០៨ ព្រឹក ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនខ្ញុំបាទតែម្តង។

៣. ជនជាប់ចោទឈ្មោះ [redacted] វណ្ណនៈ ហៅ លីន បានឆ្លើយនៅមុខតុលាការថា៖ ខ្ញុំបាទសូមសារភាពថា ខ្ញុំបាទពិតជាបានចូលរួមធ្វើសកម្មភាពលួចម៉ូតូរបស់ជនរងគ្រោះពិតប្រាកដមែន។ កាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៩ វេលាម៉ោងប្រហែល ១០ យប់ ខ្ញុំបាទ និងមិត្តភក្តិរបស់ខ្ញុំចំនួន ០៦នាក់ទៀតមានឈ្មោះ [redacted] រិទ្ធ ឈ្មោះ [redacted] សុខឡេង ឈ្មោះ [redacted] វុទ្ធី,ឈ្មោះ [redacted] ឧត្តម ឈ្មោះ [redacted] និងឈ្មោះ ង៉ាន់ ចេញពីផឹកស៊ីនៅកោះពេជ្រដោយជិះ ម៉ូតូចំនួន ០៤គ្រឿង បម្រុងនាំគ្នាទៅផ្ទះ រួចក៏ជួបជនរងគ្រោះចំនួន ០៦នាក់ មិនស្គាល់ឈ្មោះដោយជិះម៉ូតូចំនួន ០២គ្រឿង នៅម្តុំមុខអគ្គស្នងការនគរបាលជាតិនៃក្រសួងមហាផ្ទៃ។ ពេលនោះខ្ញុំបាទ និងមិត្តភក្តិរបស់ខ្ញុំបាន ជិះម៉ូតូដេញវាយជនរងគ្រោះរហូតដល់ចំណុចមុខការ៉ាសសាំងតេលាស្ពានអាកាសក្បាលថ្នល់ ដោយជនរងគ្រោះចំនួន ០៣ នាក់ បានរត់ចូលម៉ាតនៅទីនោះ។ រួចខ្ញុំបាទ និងបក្ខពួកក៏នាំគ្នាបត់ម៉ូតូទៅផ្ទះវិញ តែដោយឃើញជនរងគ្រោះផ្សេង



Scanned with CamScanner

ទៀតជិះម៉ូតូម៉ាកសង់សេ១២៥ ស៊េរីឆ្នាំ២០១៨ គប់ដុំថ្មទៅលើខ្ញុំបាទ និងមិត្តភក្តិ ពួកខ្ញុំបាននាំគ្នាជិះម៉ូតូដេញតាម ហើយជនរងគ្រោះក៏ផ្តួលម៉ូតូនៅម្តុំវត្តនិរោធ រួចខ្ញុំបាទ និងបក្ខពួកក៏យកម៉ូតូរបស់ជនរងគ្រោះទៅផ្ទះសំណាក់ម្តុំតាខ្មៅ និងបន្តដំណើរទៅខេត្តកំពតតែម្តង។ ខ្ញុំបាទ និងមិត្តភក្តិបានលក់ម៉ូតូនោះទៅឲ្យឈ្មោះ [redacted] រាជ ក្នុងតម្លៃ ៥៥០ (ប្រាំរយហាសិប) ដុល្លារអាមេរិក។

៤. ជនជាប់ចោទឈ្មោះ [redacted] សុខឡេង បានឆ្លើយនៅមុខតុលាការថា៖ ខ្ញុំបាទសូមសារភាពថា ខ្ញុំបាទពិតជាបានចូលរួមធ្វើសកម្មភាពលួចម៉ូតូរបស់ជនរងគ្រោះពិតប្រាកដមែន។ កាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៩ វេលាម៉ោងប្រហែល ១០ យប់ ខ្ញុំបាទ និងមិត្រភក្តិរបស់ខ្ញុំចំនួន ០៦ នាក់ទៀតមានឈ្មោះ [redacted] រិទ្ធ ឈ្មោះ [redacted] រតនៈ ឈ្មោះ [redacted] វុទ្ធី ឈ្មោះ [redacted] ឧត្តម ឈ្មោះ [redacted] និងឈ្មោះ ង៉ាន់ ចេញពីផឹកស៊ីនៅកោះពេជ្រដោយជិះម៉ូតូចំនួន ០៤ គ្រឿង បម្រុងនាំគ្នាទៅផ្ទះ រួចក៏បានជួបជនរងគ្រោះចំនួន ០៦ នាក់ មិនស្គាល់ឈ្មោះដោយជិះម៉ូតូចំនួន ០២ គ្រឿង នៅម្តុំមុខអគ្គស្នងការនគរបាលជាតិនៃក្រសួងមហាផ្ទៃ។ ពេលនោះខ្ញុំបាទ និងមិត្តភក្តិរបស់ខ្ញុំបានជិះម៉ូតូដេញវាយជនរងគ្រោះរហូតដល់ចំណុចមុខការ៉ាសសាំងតេលាស្ពានអាកាសក្បាលថ្នល់ដោយជនរងគ្រោះចំនួន ០៣ នាក់ បានរត់ចូលម៉ាតនៅទីនោះ រួចខ្ញុំបាទ និងបក្ខពួកក៏នាំគ្នាបត់ម៉ូតូទៅផ្ទះវិញ តែដោយឃើញជនរងគ្រោះផ្សេងទៀតជិះម៉ូតូម៉ាកសង់សេ ១២៥ ស៊េរីឆ្នាំ២០១៨ ជិះទៅម្តុំវត្តនិរោធ ពួកខ្ញុំបាននាំគ្នាជិះម៉ូតូដេញតាម ហើយជនរងគ្រោះ ក៏ផ្តួលម៉ូតូនៅម្តុំវត្តនិរោធ រួចខ្ញុំបាទ និងបក្ខពួកក៏យកម៉ូតូរបស់ជនរងគ្រោះទៅផ្ទះសំណាក់ម្តុំតាខ្មៅ និងបន្តដំណើរ ទៅខេត្តកំពតតែម្តង។ ខ្ញុំបាទ និងមិត្តភក្តិបានលក់ម៉ូតូនោះទៅឲ្យឈ្មោះ [redacted] រាជ ក្នុងតម្លៃ ៥៥០ (ប្រាំរយហាសិប) ដុល្លារអាមេរិក។

៥. ជនជាប់ចោទឈ្មោះ [redacted] វុទ្ធី បានឆ្លើយនៅមុខតុលាការថា ខ្ញុំបាទសូមសារភាពថា ខ្ញុំបាទពិតជាបានចូលរួមធ្វើសកម្មភាពលួចម៉ូតូរបស់ជនរងគ្រោះពិតប្រាកដមែន។ កាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៩ វេលាម៉ោងប្រហែល ១០ យប់ ខ្ញុំបាទ និងមិត្រភក្តិរបស់ខ្ញុំចំនួន ០៦ នាក់ទៀត មានឈ្មោះ [redacted] រិទ្ធ ឈ្មោះ [redacted] រាជ ឈ្មោះ [redacted] សុខឡេង ឈ្មោះ [redacted] ឧត្តម ឈ្មោះ [redacted] និងឈ្មោះ ង៉ាន់ ចេញពីផឹកស៊ីនៅកោះពេជ្រដោយជិះម៉ូតូចំនួន ០៤ គ្រឿង បម្រុងនាំគ្នាទៅផ្ទះ រួចក៏ជួបជនរងគ្រោះចំនួន ០៦ នាក់ មិនស្គាល់ឈ្មោះដោយជិះម៉ូតូចំនួន ០២ គ្រឿង នៅម្តុំមុខអគ្គស្នងការនគរបាលជាតិនៃក្រសួងមហាផ្ទៃ។ ពេលនោះខ្ញុំបាទ និងមិត្តភក្តិរបស់ខ្ញុំបានជិះម៉ូតូដេញវាយជនរងគ្រោះរហូតដល់ចំណុចមុខការ៉ាសសាំងតេលាស្ពានអាកាសក្បាលថ្នល់ដោយជនរងគ្រោះចំនួន ០៣ នាក់ បានរត់ចូលម៉ាតនៅទីនោះ រួចខ្ញុំបាទ និងបក្ខពួកក៏នាំគ្នាបត់ម៉ូតូទៅផ្ទះវិញ តែដោយឃើញជនរងគ្រោះ ផ្សេងទៀតជិះម៉ូតូម៉ាកសង់សេ ១២៥ ស៊េរីឆ្នាំ២០១៨ គប់ដុំថ្មទៅលើខ្ញុំបាទ និងមិត្តភក្តិ ពួកខ្ញុំបាននាំគ្នាជិះម៉ូតូ ដេញតាម ហើយជនរងគ្រោះក៏ផ្តួលម៉ូតូនៅម្តុំវត្តនិរោធ រួចខ្ញុំបាទ និងបក្ខពួកក៏យកម៉ូតូជិះចេញទៅ។ ម៉ូតូលួចគេមកពេលគឺលក់ទៅឲ្យឈ្មោះ [redacted] រាជ ដោយផ្ញើរលុយចំនួន ៥៥០ ដុល្លារអាមេរិក ដោយផ្ញើរលុយតាមវីងមកឲ្យពួកខ្ញុំ។ ពួកខ្ញុំបានជិះម៉ូតូដើរ លេងនៅខេត្តកំពត ដោយដេក បីយប់ ទើបត្រឡប់មក វិញ ដោយបែកគ្នានៅតាខ្មៅ នៅពេលដើរលេងនោះ គឺចាយលុយលក់ម៉ូតូដែលពួកខ្ញុំលួចគេមកនោះ ។

៦. ជនជាប់ចោទឈ្មោះ [redacted] រាជ បានឆ្លើយនៅមុខតុលាការថា៖ ខ្ញុំបាទសូមទទួលស្គាល់ថា ពិតជាបានទិញម៉ូតូដែលឈ្មោះ [redacted] រិទ្ធ និងឈ្មោះ [redacted] រតនៈ ហៅ លីន បានលួចពីគេមមកពិតមែន។ នៅថ្ងៃខែមិនចាំខ្ញុំចេញពីធ្វើការពីអោជនីយដ្ឋានវីហ្វេនបឹងត្របែក មកគេងនៅផ្ទះជួលម្តុំខារ៉ាអូខេគ្រួសារយើហោឡាលីន។ លុះម៉ោង ២ ទៀបភ្លឺ ស្រាប់តែមិត្តភក្តិរបស់ខ្ញុំឈ្មោះ [redacted] រិទ្ធ បានខលមកសួរខ្ញុំថាចង់ទិញម៉ូតូឬទេ? ព្រោះវាចង់លក់ម៉ូតូរបស់វា វាថាជាម៉ូតូរបស់វាផ្ទាល់មានកាតគ្រីត្រឹមត្រូវ។ វានិយាយថា "អញឃើញហ្វេងអត់ម៉ូតូជិះ អញលក់ឲ្យថោក ម៉ូតូ



Scanned with CamScanner

ម៉ាកសង់១២៥ ឆ្នាំ២០១៩ តម្លៃ ៥៥០ (ប្រាំរយហាសិប) ដុល្លារអាមេរិក បើហ្អែងចង់បានផ្ញើលុយឱ្យអញតាមវីងស្អែកព្រឹក"។ ខ្ញុំជឿជាក់វាព្រោះជាមិត្តភក្តិជាមួយគ្នាតាំងពីតូច។ លុះព្រឹកឡើងម៉ោងប្រហែល ៩ ព្រឹក ខ្ញុំក៏ផ្ញើលុយដែលខ្ញុំខំធ្វើការសន្សំជាយូរមក ហើយឱ្យវាតាមវីង។ លុះបីថ្ងៃក្រោយមកវាណាត់ខ្ញុំឱ្យទៅយកម៉ូតូនៅតាខ្មៅ។ ខ្ញុំក៏បានទៅយកម៉ូតូឃើញពួកវា មានគ្នា ៣នាក់ ជិះម៉ូតូ ២គ្រឿង ដែលក្នុងនោះម៉ូតូមួយគ្រឿងជាម៉ូតូដែលខ្ញុំទិញ និងម៉ូតូមួយគ្រឿងទៀតជារបស់ ឈ្មោះ ងាន់។ ពេលប្រគល់ម៉ូតូខ្ញុំបានមើលកាតគ្រីត្រឹមត្រូវហើយក៏យកម៉ូតូជិះមកផ្ទះតែម្តង ដោយមិនបានធ្វើលិខិតលក់ទិញអ្វីទេ ព្រោះមិត្តភក្តិស្គាល់គ្នាយូរហើយ។ ខ្ញុំមិនដឹងថាម៉ូតូនោះជាម៉ូតូដែលបានពីការប្លន់នោះទេ ប្រសិនបើដឹងក៏ខ្ញុំមិនទិញដែរ។ ចំពោះតម្លៃវិញ គឺមានតម្លៃថោក ព្រោះថាអ្នកលក់ជាមិត្តភក្តិជាមួយគ្នាតាំងពីតូច។

៧. ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុផាន់ណា បានឆ្លើយនៅចំពោះមុខតុលាការថា៖ នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៩ វេលាម៉ោង ០៣ និង ០០ នាទី រំលងអាធ្រាត ខ្ញុំបានជិះម៉ូតូម៉ាកហុងដា សេ១២៥ ស៊េរីឆ្នាំ២០១៨ ចំនួន ០២ គ្រឿង ជិះគ្នា ៦ នាក់ ទិសដៅពីវត្តបុទុម ទៅផ្ទះនៅឯច្បារអំពៅ។ លុះជិះមកដល់ចំណុចជិតអគ្គស្នងការដ្ឋាននគរបាលជាតិ ក៏ស្រាប់តែមានបក្ខពួកមួយក្រុមមានគ្នាប្រហែលជា ៧ ម៉ូតូ ជិះគ្នាប្រហែលជាងដប់នាក់ បានជិះតាមម៉ូតូរបស់ខ្ញុំ មិនដឹងមានគោលបំណងអ្វីនោះទេ។ ពេលនោះខ្ញុំ និងបក្ខពួករបស់ខ្ញុំភ័យពេកក៏ជិះរត់រហូតទៅដល់ស្តូបវត្តនិរោធន៍ ក៏ដួលម៉ូតូ ហើយក៏ត្រូវពួកនោះទាញកាំបិតកាប់ពួកខ្ញុំតែម្តង ពេលនោះខ្ញុំក៏រត់ចោលម៉ូតូ ហើយក៏ត្រូវពួកវាជិះម៉ូតូរបស់ខ្ញុំយកទៅបាត់ ។ ក្រោយមកខ្ញុំក៏បានទៅដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍នគរបាលរដ្ឋបាលវត្តនិរោធ។ រយៈពេលប្រហែលមួយខែកន្លះក្រោយមកទើបរកឃើញម៉ូតូរបស់ខ្ញុំវិញ។ ខ្ញុំបាទសូមទាមទារសំណងចំនួន ៨.០០០.០០០ (ប្រាំបីលាន) រៀល។

៨. ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សែនដារ័ត្ន បានឆ្លើយនៅ ចំពោះមុខតុលាការថា៖ នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៩ វេលាម៉ោង ០៣ និង ០០ នាទី រំលងអាធ្រាត ខ្ញុំបាទបានជិះម៉ូតូម៉ាកហុងដា សេ១២៥ ស៊េរីឆ្នាំ២០១៨ ចំនួន ០២ គ្រឿង ជិះគ្នា ៦ នាក់ ទិសដៅពីវត្តបុទុម ទៅផ្ទះនៅឯច្បារអំពៅ។ លុះជិះមកដល់ចំណុចជិតអគ្គស្នងការដ្ឋាននគរបាលជាតិ ក៏ស្រាប់តែមានបក្ខពួកមួយក្រុមមានគ្នាប្រហែលជា៧ម៉ូតូ ជិះគ្នាប្រហែលជាងដប់នាក់បានជិះតាមម៉ូតូរបស់ខ្ញុំ មិនដឹងមានគោលបំណងអ្វីនោះទេ។ ពេលនោះខ្ញុំ និងបក្ខពួករបស់ខ្ញុំភ័យពេកក៏ជិះរត់រហូតទៅដល់ហ្គារាសសាំងតេលា នៅជិតអគ្គស្នងការស្រាប់តែពួកវាបានយកខ្សែក្រវ៉ាត់ មកវាយលើខ្ញុំបាទ និងបក្ខពួករបស់ខ្ញុំ បណ្តាលឱ្យរងរបួស ហើយពួកវាក៏បានវាយម៉ូតូរបស់ខ្ញុំបាទខ្ទេចខ្ទីអស់។ ខ្ញុំបាទសូមទាមទារសំណងចំនួន ៨.០០០.០០០ (ប្រាំបីលាន) រៀល។

៩. តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ឆ្លងតាមការសួរដេញដោលនាពេលសវនាការនេះ ឃើញថាជនជាប់ចោទឈ្មោះ [redacted] រិទ្ធ ឈ្មោះ [redacted] វុទ្ធី ឈ្មោះ [redacted] វណ្ណធៈ ឈ្មោះ [redacted] ឧត្តម ឈ្មោះ [redacted] សុខឡេង បានឆ្លើយសារភាពថាខ្លួនពិតជាបានប្រព្រឹត្តនូវអំពើ លួច មានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ចំណែកឈ្មោះ [redacted] រាជ ក៏បានឆ្លើយសារភាពថាខ្លួនបានទទួលទិញម៉ូតូពី ជនជាប់ចោទខាងលើដែរ ដូចនេះអំពើរបស់ជនជាប់ចោទឈ្មោះ [redacted] រាជ គឺជាអំពើទទួលផលចោរកម្ម ពិតប្រាកដមែន។ ដូច្នេះ តាមចម្លើយ របស់ជនជាប់ចោទទាំង ៦ នាក់ និងតាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងភស្តុតាងផ្សេងៗដែលមានក្នុងសំណុំរឿង គឺមានភាពស៊ីសង្វាក់ទៅហ្នឹងអង្គហេតុដែលបានកើតឡើង។ ដូចនេះ តំណាងអយ្យការសូមរក្សាបទចោទប្រកាន់ តាមដីកាសន្និដ្ឋានស្ថាពរ លេខ ១៤១២ អ.យ.ផ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ទុកនៅដដែល និងប្តឹងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។



Scanned with CamScanner

១០. លោកមេធាវី [redacted] និងលោក មេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទទាំងប្រាំមួយនាក់ បានធ្វើសេចក្តីសន្និដ្ឋានការពារថា ឆ្លងតាមការសួរដេញដោលនាពេលសវនាការនេះ ឃើញថា កូនក្តីខ្ញុំបាទទាំងប្រាំមួយនាក់ បានឆ្លើយសារភាព នូវអំពើដែលខ្លួនបានប្រព្រឹត្ត ជូនអង្គសវនាការអស់ហើយ។ ដូច្នេះ ឃើញថា កូនក្តីខ្ញុំបាទ គឺបានដឹងនូវកំហុសរបស់ខ្លួនដែលបានប្រព្រឹត្ត ដូចនេះ ខ្ញុំបាទស្នើសុំឱ្យប្រធានក្រុមប្រឹក្សាជំនុំជម្រះ មេត្តាបន្ធូបន្ថយទោសដល់កូនក្តីខ្ញុំបាទទាំងប្រាំមួយនាក់ផង។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

- ជនជាប់ចោទឈ្មោះ [redacted] រិទ្ធ បាននិយាយសំដីចុងក្រោយបង្អស់ថា ខ្ញុំបាទសំណូមពរដល់តុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់ខ្ញុំផង ខ្ញុំដឹងខុសហើយ។
- ជនជាប់ចោទឈ្មោះ [redacted] ឧត្តម បាននិយាយសំដីចុងក្រោយបង្អស់ថាខ្ញុំបាទសំណូមពរតុលាការ បន្ធូរបន្ថយទោសដល់ខ្ញុំបាទផង ខ្ញុំបាទដឹងខ្លួនខុសហើយ ។
- ជនជាប់ចោទឈ្មោះ [redacted] វឌ្ឍនៈ បាននិយាយសំដីចុងក្រោយបង្អស់ថាខ្ញុំបាទសំណូមពរ សុំឱ្យតុលាការជួយសម្រាលទោសដល់ខ្ញុំបាទផង ព្រោះខ្ញុំបាទដឹងកំហុសហើយ។
- ជនជាប់ចោទឈ្មោះ [redacted] សុខឡេង បាននិយាយសំដីចុងក្រោយបង្អស់ថាខ្ញុំបាទសំណូមពរសុំ ឱ្យតុលាការជួយសម្រាលទោសដល់ខ្ញុំបាទផង ព្រោះខ្ញុំបាទដឹងកំហុសហើយ ។
- ជនជាប់ចោទឈ្មោះ [redacted] វុទ្ធី បាននិយាយសំដីចុងក្រោយបង្អស់ថាខ្ញុំបានសំណូមពរដល់តុលាការមេត្តាបន្ធូរបន្ថយទោសដល់ខ្ញុំផង ព្រោះខ្ញុំដឹងខ្លួនខុសហើយ។
- ជនជាប់ចោទឈ្មោះ [redacted] រាជ បាននិយាយសំដីចុងក្រោយបង្អស់ថាខ្ញុំបាទសំណូមពរដល់តុលាការមេត្តាបន្ធូរបន្ថយទោសដល់ខ្ញុំផង ព្រោះខ្ញុំដឹងខ្លួនខុសហើយ។

- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
- ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ
- ក្រោយពីបានពិនិត្យលើឯកសារភស្តុតាងនានា
- ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

១. ឃើញថាតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] រិទ្ធ បានឆ្លើយនៅមុខតុលាការថា ខ្លួនសូមទទួលយកការចោទប្រកាន់របស់តំណាងអយ្យការ ដែលបានចោទខ្លួនពីបទលួច ដោយនៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៩ វេលាម៉ោងប្រហែល ៨ យប់ ខ្លួនកំពុងនៅផ្ទះ ហើយខលហៅមិត្តភក្តិខ្លួនឈ្មោះ [redacted] វុទ្ធី មកយកខ្លួនទៅដើរលេងកោះពេជ្រ ឈ្មោះ [redacted] វុទ្ធី បានជិះម៉ូតូម៉ាកនិច មកយកខ្លួនជិះទៅដើរលេងកោះពេជ្រ។ ពេលទៅដល់ខ្លួនបានជួបឈ្មោះ [redacted] សុខឡេង ឈ្មោះ [redacted] វឌ្ឍនៈ ឈ្មោះ [redacted] ឧត្តម ឈ្មោះ [redacted] ឈ្មោះ ងាន់ ដែលកំពុងផឹកប៊ីយែរនៅកោះពេជ្រ។ សរុបទាំងខ្លួន និងឈ្មោះ [redacted] វុទ្ធី គឺមានគ្នា ០៧ នាក់។ លុះម៉ោងជិត ១០ យប់ ពួកខ្លួនបានចេញពីកោះពេជ្រមកផឹកស្រាឈុតនៅមុខណាហ្គា។ ពួកខ្លួនផឹករហូតដល់ម៉ោងប្រហែល៣ ភ្លឺ ក៏ឈប់ផឹកនាំគ្នាជិះម៉ូតូទៅផ្ទះវិញ។ ពេលជិះចេញមកវិញមានគ្នា ៧ នាក់ ជិះម៉ូតូ ៤ ដដែល។ លុះជិះមកដល់មុខក្រសួងមហាផ្ទៃ ស្រាប់តែ



Scanned with CamScanner

ជួបមនុស្សប្រុស បី នាក់ ជិះម៉ូតូមួយគ្រឿង ដែលធ្លាប់មានជម្លោះជាមួយខ្លួន ពួកខ្លួនក៏បាននាំគ្នាដេញវាយពួកទាំងអស់នោះ។ ពេលនោះមានមនុស្សប្រុស បី នាក់ ជិះម៉ូតូមួយគ្រឿងចូលការ៉ាស់សាំងតេលា ជាប់របងអគ្គស្នងការដ្ឋាននគរបាលជាតិ ផ្តួលម៉ូតូចោល ហើយរត់ចូលម៉ាតតេលា។ ពួកខ្លួនមិនបានចូលវាយវាទេ។ ស្រាប់តែឈ្មោះ [redacted] វឌ្ឍនៈ ហៅ លីន ស្រែកថាមានគ្នាវាម្នាក់ជិះម៉ូតូម្នាក់ឯងរត់គេចខ្លួនទៅមុខ។ ឈ្មោះ [redacted] វឌ្ឍនៈ ហៅ លីន បានជិះម៉ូតូដោយមានឈ្មោះ [redacted] សុខឡេង ជាអ្នកឌុប ជិះដេញជនរងគ្រោះម្នាក់នោះទៅដល់មុខវត្តនិរោធ។ ខ្លួននិងឈ្មោះ [redacted] វុទ្ធី ឈ្មោះ [redacted] ឧត្តម ឈ្មោះ [redacted] ឈ្មោះ ងាន់ ក៏ជិះម៉ូតូ បីគ្រឿងដេញតាមពីក្រោយ។ ពេលទៅដល់ជនរងគ្រោះបត់ម៉ូតូក៏រអិលដួល ហើយឈ្មោះ [redacted] វឌ្ឍនៈ ហៅ លីន បានចុះទៅលើកម៉ូតូជនរងគ្រោះយកម៉ូតូជនរងគ្រោះជិះត្រឡប់មកវិញមកតាមវត្តកំសាន្ត ហើយក៏បបួលគ្នាជិះដើរលេងទៅខេត្តកំពត ពួកខ្លួនជិះទៅដល់ខេត្តកំពតនៅម៉ោងប្រហែល ៧ ភ្លឺ ថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩។ ឈ្មោះ [redacted] វឌ្ឍនៈ ហៅ លីន បានខលសួរឈ្មោះ [redacted] រាជ ថាចង់ទិញម៉ូតូឬទេ?។ ឈ្មោះ [redacted] រាជ ហើយឈ្មោះ [redacted] រាជ បានសួរថា ម៉ូតូរបស់អ្នកណា? ពេលនោះឈ្មោះ [redacted] វឌ្ឍនៈ ហៅ លីន ក៏បានប្រាប់ទៅវិញថា ម៉ូតូលួចគេមក ពេលនោះឈ្មោះ [redacted] រាជ ក៏បានទិញម៉ូតូនោះ ដោយផ្ញើរលុយចំនួន ៥៥០ ដុល្លារអាមេរិក ដោយផ្ញើរលុយតាមវីងមកឲ្យពួកខ្លួន។ ពួកខ្លួនបានជិះម៉ូតូដើរលេងនៅខេត្តកំពត ដោយដេក បី យប់ ទើបត្រឡប់មកវិញ។ ដោយបែកគ្នានៅតាខ្មៅ នៅពេលដើរលេងនោះ គឺចាយលុយលក់ម៉ូតូដែលពួកខ្លួនលួចគេមកនោះ។ នៅពេលមកដល់តាខ្មៅ ឈ្មោះ [redacted] រាជ បានមកយកម៉ូតូ។ លុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៩ ម៉ោងប្រហែល ០៨ ព្រឹក ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង។

២. ឃើញថាតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ឧត្តម បានឆ្លើយនៅមុខតុលាការថា៖ ខ្លួនសូមសារភាពថាខ្លួនពិតជាបានចូលរួមធ្វើសកម្មភាពលួចម៉ូតូរបស់ជនរងគ្រោះពិតប្រាកដមែន។ ដោយនៅថ្ងៃកើតហេតុខ្លួន រួមមួយបក្សពួក ០៧ នាក់ ទៀត ដោយមានឈ្មោះ [redacted] រិទ្ធ ឈ្មោះ [redacted] សុខឡេង ឈ្មោះ [redacted] វឌ្ឍនៈ ឈ្មោះ [redacted] វុទ្ធី ឈ្មោះ [redacted] ឈ្មោះ ង៉ាន់ និងរូបខ្លួន។ លុះជិះមកដល់មុខក្រសួងមហាផ្ទៃស្រាប់តែជួបមនុស្សប្រុស បីនាក់ជិះម៉ូតូមួយគ្រឿង ដែលធ្លាប់មានជម្លោះជាមួយឈ្មោះ [redacted] រិទ្ធ ពេលនោះពួកខ្លួនក៏បាននាំគ្នា ដេញវាយពួកទាំងអស់នោះ។ ស្រាប់តែឈ្មោះ [redacted] វឌ្ឍនៈ ហៅ លីន ស្រែកថាមានគ្នាវាម្នាក់ជិះម៉ូតូម្នាក់ឯងរត់គេចខ្លួនទៅមុខ។ ឈ្មោះ [redacted] វឌ្ឍនៈ ហៅ លីន បានជិះម៉ូតូដោយមានឈ្មោះ [redacted] សុខឡេង ជាអ្នកឌុបជិះដេញជនរងគ្រោះម្នាក់នោះទៅដល់មុខវត្តនិរោធ។ ពេលទៅដល់ជនរងគ្រោះបត់ម៉ូតូក៏រអិលដួលហើយឈ្មោះ [redacted] វឌ្ឍនៈ ហៅ លីន បានចុះទៅលើកម៉ូតូជនរងគ្រោះ យកម៉ូតូជនរងគ្រោះជិះត្រឡប់មកវិញមកតាមវត្តកំសាន្ត ហើយក៏បបួលគ្នាជិះ ដើរលេងទៅខេត្តកំពត ពួកខ្លួនជិះទៅដល់ខេត្តកំពតនៅម៉ោងប្រហែល ៧ ភ្លឺ ថ្ងៃទី១៧ ខែមករា ឆ្នាំ ២០១៩។ ឈ្មោះ [redacted] វឌ្ឍនៈ ហៅ លីន បានខលសួរឈ្មោះ [redacted] រាជ ថាចង់ទិញម៉ូតូឬទេ។ ហើយឈ្មោះ [redacted] រាជ បានសួរថា ម៉ូតូរបស់អ្នកណា? ពេលនោះឈ្មោះ [redacted] វឌ្ឍនៈ ហៅ លីន ក៏បានប្រាប់ទៅវិញថា ម៉ូតូលួចគេមក ពេលនោះឈ្មោះ [redacted] រាជ ក៏បានទិញម៉ូតូនោះ ដោយផ្ញើរលុយចំនួន ៥៥០ ដុល្លារអាមេរិក ដោយផ្ញើរលុយតាមវីងមកឲ្យពួកខ្លួន។ ពួកខ្លួនបានជិះម៉ូតូដើរលេងនៅខេត្តកំពត ដោយដេក បីយប់ ទើបត្រឡប់មកវិញ ដោយបែកគ្នានៅតាខ្មៅ នៅពេលដើរលេងនោះ គឺចាយលុយលក់ម៉ូតូដែលពួកខ្លួនលួចគេមកនោះ។ នៅពេលមកដល់តាខ្មៅ ឈ្មោះ [redacted] រាជ បានមកយកម៉ូតូ។ លុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៩ ម៉ោងប្រហែល ០៨ ព្រឹក ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង។



Scanned with CamScanner

៣. ឃើញថាតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] វណ្ណនៈ ហៅ លីន បានឆ្លើយនៅមុខតុលាការថា ខ្លួនសូមសារភាពថា ខ្លួនពិតជាបានធ្វើសកម្មភាពលួចម៉ូតូរបស់ជនរងគ្រោះពិតប្រាកដមែន។ កាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៩ វេលាម៉ោងប្រហែល ១០ យប់ ខ្លួន និងមិត្តភក្តិរបស់ខ្លួនចំនួន ០៦ នាក់ ទៀតមានឈ្មោះ [redacted] រិទ្ធ ឈ្មោះ [redacted] សុខឡេង ឈ្មោះ [redacted] វុទ្ធី ឈ្មោះ [redacted] ឧត្តម ឈ្មោះ មាន និងឈ្មោះ ង៉ាន់ ចេញពីផឹកស៊ីនៅកោះពេជ្រ ដោយជិះម៉ូតូចំនួន ០៤ គ្រឿង បម្រុងនាំគ្នាទៅផ្ទះ រួចក៏ជួបជនរងគ្រោះចំនួន ០៦ នាក់ មិនស្គាល់ឈ្មោះដោយជិះម៉ូតូចំនួន ០២ គ្រឿង នៅម្តុំមុខអគ្គស្នងការនគរបាលជាតិនៃក្រសួងមហាផ្ទៃ។ ពេលនោះខ្លួន និងមិត្តភក្តិរបស់ខ្លួនបាន ជិះម៉ូតូដេញវាយជនរងគ្រោះរហូតដល់ចំណុចមុខការ៉ាសសាំងតេលាស្ពានអាកាសក្បាលថ្នល់ ដោយជនរងគ្រោះចំនួន ០៣ នាក់ បានរត់ចូលម៉ាតនៅទីនោះ។ រួចខ្លួន និងបក្ខពួកក៏នាំគ្នាបត់ម៉ូតូទៅផ្ទះវិញ តែដោយឃើញជនរងគ្រោះផ្សេងទៀតជិះម៉ូតូម៉ាកសង់សេ១២៥ ស៊េរីឆ្នាំ២០១៨ គប់ដុំថ្មទៅលើខ្លួន និងមិត្តភក្តិ ពួកខ្លួនបាននាំគ្នាជិះម៉ូតូដេញតាម ហើយជនរងគ្រោះក៏ផ្តួលម៉ូតូនៅម្តុំវត្តនិរោធ រួចខ្លួន និងបក្ខពួកក៏យកម៉ូតូរបស់ជនរងគ្រោះទៅផ្ទះសំណាក់ម្តុំតាខ្មៅ និងបន្តដំណើរទៅខេត្តកំពតតែម្តង។ ខ្លួន និងមិត្តភក្តិបានលក់ម៉ូតូនោះទៅឲ្យឈ្មោះ [redacted] រាជ ក្នុងតម្លៃ ៥៥០ (ប្រាំរយហាសិប) ដុល្លារអាមេរិក។

៤. ឃើញថាតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុខឡេង បានឆ្លើយនៅមុខតុលាការថា៖ ខ្លួនសូមសារភាពថា ខ្លួនពិតជាបានចូលរួមធ្វើសកម្មភាពលួចម៉ូតូរបស់ជនរងគ្រោះពិតប្រាកដមែន។ កាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៩ វេលាម៉ោងប្រហែល ១០ យប់ ខ្លួន និងមិត្តភក្តិរបស់ខ្លួនចំនួន ០៦ នាក់ទៀត មានឈ្មោះ [redacted] រិទ្ធ ឈ្មោះ [redacted] រតនៈ ឈ្មោះ [redacted] វុទ្ធី ឈ្មោះ [redacted] ឧត្តម ឈ្មោះ [redacted] និងឈ្មោះ ង៉ាន់ ចេញពីផឹកស៊ីនៅកោះពេជ្រដោយជិះម៉ូតូចំនួន ០៤ គ្រឿង បម្រុងនាំគ្នាទៅផ្ទះ រួចក៏បានជួបជនរងគ្រោះចំនួន ០៦ នាក់ មិនស្គាល់ឈ្មោះដោយជិះម៉ូតូចំនួន ០២ គ្រឿង នៅម្តុំមុខអគ្គស្នងការនគរបាលជាតិនៃក្រសួងមហាផ្ទៃ។ ពេលនោះខ្លួន និងមិត្តភក្តិរបស់ខ្លួនបានជិះម៉ូតូដេញវាយជនរងគ្រោះរហូតដល់ចំណុចមុខការ៉ាសសាំងតេលាស្ពានអាកាសក្បាលថ្នល់ ដោយជនរងគ្រោះចំនួន ០៣ នាក់ បានរត់ចូលម៉ាតនៅទីនោះ រួចខ្លួន និងបក្ខពួកក៏នាំគ្នាបត់ម៉ូតូទៅផ្ទះវិញ តែដោយឃើញជនរងគ្រោះផ្សេងទៀតជិះម៉ូតូម៉ាកសង់សេ ១២៥ ស៊េរីឆ្នាំ២០១៨ ជិះទៅម្តុំវត្តនិរោធ ពួកខ្លួនបាននាំគ្នាជិះម៉ូតូដេញតាម ហើយជនរងគ្រោះ ក៏ផ្តួលម៉ូតូនៅម្តុំវត្តនិរោធ រួចខ្លួន និងបក្ខពួកក៏យកម៉ូតូរបស់ជនរងគ្រោះទៅផ្ទះសំណាក់ម្តុំតាខ្មៅ និងបន្តដំណើរទៅខេត្តកំពតតែម្តង។ ខ្លួន និងមិត្តភក្តិបានលក់ម៉ូតូនោះទៅឲ្យឈ្មោះ [redacted] រាជ ក្នុងតម្លៃ ៥៥០ (ប្រាំរយហាសិប) ដុល្លារអាមេរិក។

៥. ឃើញថាតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] វុទ្ធី បានឆ្លើយនៅមុខតុលាការថា ខ្លួនសូមសារភាពថា ខ្លួនពិតជាបានចូលរួមធ្វើសកម្មភាពលួចម៉ូតូរបស់ជនរងគ្រោះពិតប្រាកដមែន។ កាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៩ វេលាម៉ោងប្រហែល ១០ យប់ ខ្លួន និងមិត្តភក្តិរបស់ខ្លួនចំនួន ០៦ នាក់ទៀត មានឈ្មោះ [redacted] រិទ្ធ ឈ្មោះ [redacted] រាជ ឈ្មោះ [redacted] សុខឡេង ឈ្មោះ [redacted] ឧត្តម ឈ្មោះ [redacted] និងឈ្មោះ ង៉ាន់ ចេញពីផឹកស៊ីនៅកោះពេជ្រដោយជិះម៉ូតូចំនួន ០៤ គ្រឿង បម្រុងនាំគ្នាទៅផ្ទះ រួចក៏ជួបជនរងគ្រោះចំនួន ០៦ នាក់ មិនស្គាល់ឈ្មោះដោយជិះម៉ូតូចំនួន ០២ គ្រឿង នៅម្តុំមុខអគ្គស្នងការនគរបាលជាតិនៃក្រសួងមហាផ្ទៃ។ ពេលនោះខ្លួន និងមិត្តភក្តិរបស់ខ្លួនបានជិះម៉ូតូដេញវាយជនរងគ្រោះរហូតដល់ចំណុចមុខការ៉ាសសាំងតេលាស្ពានអាកាសក្បាលថ្នល់ ដោយជនរងគ្រោះចំនួន ០៣ នាក់ បានរត់ចូលម៉ាតនៅទីនោះ រួចខ្លួន និងបក្ខពួកក៏នាំគ្នាបត់ម៉ូតូទៅផ្ទះវិញ តែដោយឃើញជនរងគ្រោះ



Scanned with CamScanner

ផ្សេងទៀតជិះម៉ូតូម៉ាកសង់សេ ១២៥ ស៊េរីឆ្នាំ២០១៨ គប់ដុំថ្មទៅលើខ្លួន និងមិត្តភក្តិ ពួកខ្លួនបានទាំគ្នាជិះម៉ូតូដេញតាម ហើយជនរងគ្រោះក៏ដួលម៉ូតូនៅម្តុំវត្តនិរោធ រួចខ្លួន និងបក្ខពួកក៏យកម៉ូតូជិះចេញទៅ។ ម៉ូតូលួចគេមកពេលគឺលក់ទៅឱ្យឈ្មោះ [redacted] រាជ ដោយផ្ញើរលុយចំនួន ៥៥០ ដុល្លាររអាមេរិក ដោយផ្ញើរលុយតាមវីងមកឱ្យពួកខ្លួន។ ពួកខ្លួនបានជិះម៉ូតូដើរលេងនៅខេត្តកំពត ដោយដេក បី យប់ ទើបត្រឡប់មកវិញ ដោយបែកគ្នានៅតាខ្មៅ នៅពេលដើរលេងនោះ គឺចាយលុយលក់ម៉ូតូដែលពួកខ្លួនលួចគេមកនោះ។

៦. ឃើញថាតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] រាជ បានឆ្លើយនៅមុខតុលាការថា ខ្លួនសូមទទួលស្គាល់ថាពិតជាបានទិញម៉ូតូ ដែលឈ្មោះ [redacted] រិទ្ធ និងឈ្មោះ [redacted] វឌ្ឍនៈ ហៅ លីន បានលួចពីគេមមកពិតមែន។ នៅថ្ងៃខែមិនចាំខ្លួនចេញពីធ្វើការ ពីភោជនីយដ្ឋានវីហ្រ្វេនបឹងត្របែក មកគេងនៅផ្ទះជួលម្តុំខាភ័រូខេគ្រួសារយីហោឡាលីន។ លុះម៉ោង ២ ទៀបភ្លឺ ស្រាប់តែមិត្តភក្តិរបស់ខ្លួនឈ្មោះ [redacted] រិទ្ធ បានខលមកសួរខ្លួនថា ចង់ទិញម៉ូតូឬទេ? ព្រោះវាចង់លក់ម៉ូតូរបស់វា វាថាជាម៉ូតូរបស់វាផ្ទាល់មានកាតគ្រីត្រឹមត្រូវ។ វានិយាយថា "អញឃើញហ្វែងអត់ម៉ូតូជិះ អញលក់ឱ្យថោក ម៉ូតូម៉ាកសង់១២៥ ឆ្នាំ២០១៩ តម្លៃ ៥៥០ (ប្រាំរយហាសិប) ដុល្លាររអាមេរិក បើហ្វែងចង់បានផ្ញើលុយឱ្យអញតាមវីងស្អែកព្រឹក"។ ខ្លួនជឿជាក់វាព្រោះជាមិត្តភក្តិជាមួយគ្នាតាំងពីតូច។ លុះព្រឹកឡើងម៉ោងប្រហែល ៩ ព្រឹក ខ្លួនក៏ផ្ញើលុយដែលខ្លួនខំធ្វើការសន្សំជាយូរមកហើយឱ្យវាតាមវីង។ លុះបីថ្ងៃក្រោយមកវាណាត់ខ្លួនឱ្យទៅយកម៉ូតូនៅតាខ្មៅ។ ខ្លួនក៏បានទៅយកម៉ូតូឃើញពួកវាមានគ្នា ៣នាក់ ជិះម៉ូតូ ២ គ្រឿង ដែលក្នុងនោះម៉ូតូមួយគ្រឿងជាម៉ូតូដែលខ្លួនទិញ និងម៉ូតូមួយគ្រឿងទៀតជារបស់ឈ្មោះ ងាន់។ ពេលប្រគល់ម៉ូតូខ្លួនបានមើលកាតគ្រីត្រឹមត្រូវហើយក៏យកម៉ូតូជិះមកផ្ទះតែម្តង ដោយមិនបានធ្វើលិខិតលក់ទិញអ្វីទេ ព្រោះមិត្តភក្តិស្គាល់គ្នាយូរហើយ។ ខ្លួនមិនដឹងថាម៉ូតូនោះជាម៉ូតូដែលបានពីការប្លន់នោះទេ ប្រសិនបើដឹងក៏ខ្លួនមិនទិញដែរ។ ចំពោះតម្លៃវិញ គឺមានតម្លៃថោក ព្រោះថាអ្នកលក់ជាមិត្តភក្តិជាមួយគ្នាតាំងពីតូច។

៧. ឃើញថាតាមការបំភ្លឺរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុផាន់ណា បានឆ្លើយបំភ្លឺនៅចំពោះមុខតុលាការថា នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៩ វេលាម៉ោង ០៣ និង ០០ នាទី រំលងអាធ្រាត ខ្លួនបានជិះម៉ូតូម៉ាកហុងដាសេ១២៥ ស៊េរីឆ្នាំ២០១៨ ចំនួន ០២ គ្រឿង ជិះគ្នា ៦ នាក់ ទិសដៅពីវត្តបុទុម ទៅផ្ទះនៅឯច្បារអំពៅ។ លុះជិះមកដល់ចំណុចជិតអគ្គស្នងការដ្ឋាននគរបាលជាតិ ក៏ស្រាប់តែមានបក្ខពួកមួយក្រុមមានគ្នាប្រហែលជា ៧ ម៉ូតូ ជិះគ្នាប្រហែលជាងដប់នាក់ បានជិះតាមម៉ូតូរបស់ខ្លួន មិនដឹងមានគោលបំណងអ្វីនោះទេ។ ពេលនោះខ្លួន និងបក្ខពួករបស់ខ្លួនភ័យពេកក៏ជិះរត់រហូតទៅដល់ស្តុបវត្តនិរោធន៍ ក៏ដួលម៉ូតូ ហើយក៏ត្រូវពួកនោះទាញកាំបិតកាប់ពួកខ្លួនតែម្តង ពេលនោះខ្លួនក៏រត់ចោលម៉ូតូ ហើយក៏ត្រូវពួកវាជិះម៉ូតូរបស់ខ្លួនយកទៅបាត់។ ក្រោយមកខ្លួនក៏បានទៅដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍នគរបាលរដ្ឋបាលវត្តនិរោធ។ រយៈពេលប្រហែលមួយខែកន្លះក្រោយមកទើបរកឃើញម៉ូតូរបស់ខ្លួនវិញ។ ខ្លួនសូមទាមទារសំណងចំនួន ៨.០០០.០០០ (ប្រាំបីលាន) រៀល។

៨. ឃើញថាតាមការបំភ្លឺរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សែនដារ័ត្ន បានឆ្លើយបំភ្លឺនៅចំពោះមុខតុលាការថា នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៩ វេលាម៉ោង ០៣ និង ០០ នាទី រំលងអាធ្រាត ខ្លួនបានជិះម៉ូតូម៉ាកហុងដា សេ១២៥ ស៊េរីឆ្នាំ២០១៨ ចំនួន ០២ គ្រឿង ជិះគ្នា ៦ នាក់ ទិសដៅពីវត្តបុទុម ទៅផ្ទះនៅឯច្បារអំពៅ។ លុះជិះមកដល់ចំណុចជិតអគ្គស្នងការដ្ឋាននគរបាលជាតិ ក៏ស្រាប់តែមានបក្ខពួកមួយក្រុមមានគ្នាប្រហែលជា៧ ម៉ូតូ ជិះគ្នា



Scanned with CamScanner

ប្រហែលជាងដប់នាក់ បានជិះតាមម៉ូតូរបស់ខ្លួន មិនដឹងមានគោលបំណងអ្វីនោះទេ។ ពេលនោះខ្លួន និងបក្ខពួករបស់ខ្លួនភ័យពេកក៏ជិះរត់រហូត ទៅដល់ហ្គារាសសាំងតេលា នៅជិតអគ្គស្នងការស្រាប់តែពួកវាបានយកខ្សែរក្រវ៉ាត់ មកវាយលើខ្លួន និងបក្ខពួករបស់ខ្លួន បណ្តាលឱ្យរងរបួស ហើយពួកវាក៏បានវាយម៉ូតូរបស់ខ្លួនខ្ទេចខ្ទីអស់។ ខ្លួនសូមទាមទារសំណងចំនួន ៨.០០០.០០០ (ប្រាំបីលាន) រៀល។

៩. ឃើញថាតំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ឆ្លងតាមការសួរដេញដោលនាពេលសវនាការនេះ ឃើញថា ជនជាប់ចោទឈ្មោះ [redacted] រិទ្ធ ឈ្មោះ [redacted] វុទ្ធី ឈ្មោះ [redacted] វឌ្ឍនៈ ឈ្មោះ [redacted] ឧត្តម ឈ្មោះ [redacted] សុខឡេង បានឆ្លើយសារភាពថា ខ្លួនពិតជាបានប្រព្រឹត្តនូវអំពើ លួច មានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ចំណែកឈ្មោះ [redacted] រាជ ក៏បានឆ្លើយសារភាពថាខ្លួនបានទទួលទិញម៉ូតូពីជនជាប់ចោទខាងលើដែរ ដូចនេះអំពើរបស់ជនជាប់ចោទឈ្មោះ [redacted] រាជ គឺជាអំពើទទួលផលចោរកម្ម ពិតប្រាកដមែន។ ដូច្នេះ តាមចម្លើយរបស់ជនជាប់ចោទទាំង ៦ នាក់ និងតាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងភស្តុតាងផ្សេងៗដែលមានក្នុងសំណុំរឿង គឺមានភាពស៊ីសង្វាក់ទៅហ្នឹងអង្គហេតុដែលបានកើតឡើង។ ដូចនេះ តំណាងអយ្យការសូមរក្សាបទចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរ លេខ ១៥១២ អ.យ.ផ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ទុកនៅដដែល និងប្តឹងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

១០. ឃើញថាលោកមេធាវី [redacted] និងលោក មេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទទាំងប្រាំមួយនាក់ បានធ្វើសេចក្តីសន្និដ្ឋានការពារថា ឆ្លងតាមការសួរដេញដោលនាពេលសវនាការនេះ ឃើញថា កូនក្តីខ្លួនទាំងប្រាំមួយនាក់ បានឆ្លើយសារភាពនូវអំពើដែលខ្លួនបានប្រព្រឹត្ត ជូនអង្គសវនាការអស់ហើយ។ ដូច្នេះ ឃើញថា កូនក្តីខ្លួន គឺបានដឹងនូវកំហុសរបស់ខ្លួនដែលបានប្រព្រឹត្ត ដូចនេះ ខ្លួនស្នើសុំឱ្យប្រធានក្រុមប្រឹក្សាជំនុំជម្រះ មេត្តាបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនទាំងប្រាំមួយនាក់ផង។

១១. យល់ឃើញថា តាមសេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ ដែលបានស្នើសុំមកតុលាការ ឱ្យតម្កល់បទចោទប្រកាន់ និងប្តឹងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់ ក៏ដូចជាសេចក្តីសន្និដ្ឋានការពាររបស់លោកមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទនោះ តុលាការ នឹងលើកមកពិនិត្យពិចារណា និងសម្រេចទៅតាមអង្គហេតុ និងអង្គច្បាប់។

១២. យល់ឃើញថា តាមចម្លើយសារភាពរបស់ជនជាប់ចោទ និងតាមការបំភ្លឺរបស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងភស្តុតាងនានា ក្នុងសំណុំរឿង កំណត់បានថា ជនជាប់ចោទទាំងប្រាំនាក់ បានប្រព្រឹត្តនូវអំពើ វាយជនរងគ្រោះ និងបានយកម៉ូតូរបស់ជនរងគ្រោះ ព្រមទាំងបានយកម៉ូតូនេះទៅលក់ចែកលុយគ្នា។ សកម្មភាពទាំងនេះ គឺជាការលួចដោយហិង្សា ដែលបានប្រព្រឹត្តមកលើជនរងគ្រោះ។ ចំណែកជនជាប់ចោទឈ្មោះ [redacted] រាជ បានដឹងនូវអំពើលួចម៉ូតូជនរងគ្រោះនេះហើយ នៅតែទិញម៉ូតូនេះ ដើម្បីប្រយោជន៍របស់ខ្លួន និងបក្ខពួកខ្លួនទាំងប្រាំនាក់ខាងលើនេះ។ ដូច្នេះ ជនជាប់ចោទឈ្មោះ [redacted] រាជ នេះ បានដឹងយ៉ាងច្បាស់ថា អំពើរបស់ខ្លួន ជាអំពើទទួលផលចោរកម្ម ហើយដែលជាអំពើខុសច្បាប់ ប៉ុន្តែខ្លួននៅតែប្រព្រឹត្ត។

១៣. យល់ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណី បានទាមទារសំណងក្នុងម្នាក់ៗចំនួន ៨.០០០.០០០ (ប្រាំបីលាន) រៀល នោះ តុលាការ នឹងលើកយកមកពិនិត្យពិចារណា នឹងសម្រេចទៅតាមអង្គហេតុ និងអង្គច្បាប់ និងសភាពជាក់ស្តែង។

១៤. ឃើញថាជនជាប់ចោទមានសតិបញ្ញាស្មារតីគ្រប់គ្រាន់ ហើយដែលមានចេតនាប្រព្រឹត្តអំពើរបស់ខ្លួន ដែលបានធ្វើឱ្យខូចសណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់បុគ្គលឯកជន។



Scanned with CamScanner

សន្និដ្ឋាន៖ ដូចបានបញ្ជាក់ក្នុងសំអាងហេតុខាងលើ តុលាការរកឃើញថា មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ដែលកំណត់ និងប្រកាសបានថាឈ្មោះ [redacted] រិទ្ធ ឈ្មោះ [redacted] វុទ្ធី ឈ្មោះ [redacted] វណ្ណនៈ ឈ្មោះ [redacted] ឧត្តម ឈ្មោះ [redacted] សុខឡេង មានពិរុទ្ធភាពពីបទ លួចមានស្ថានទម្ងន់ ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ជាបទល្មើសដែលមានបញ្ញត្តិ និងផ្តន្ទាទោសតាមមាត្រា ៣៥៣ មាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ និងឈ្មោះ [redacted] រាជ មានពិរុទ្ធភាពពីបទ ទទួលផលចោរកម្ម ជាបទល្មើសដែលមានបញ្ញត្តិនិងផ្តន្ទាទោសតាមមាត្រា ៣៩៩និងមាត្រា ៤០០នៃក្រមព្រហ្មទណ្ឌ។

## ហេតុដូច្នេះសម្រេច

១. ផ្តន្ទាទោសឈ្មោះ [redacted] រិទ្ធ ឈ្មោះ [redacted] វុទ្ធី ឈ្មោះ [redacted] វណ្ណនៈ ឈ្មោះ [redacted] ឧត្តម ឈ្មោះ [redacted] សុខឡេង ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចផ្លូវជាតិលេខ១ កែងផ្លូវលេខ៣៥១ ភូមិតាងៅ សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៩ ជាបទល្មើសដែលមានបញ្ញត្តិ និងផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២. ផ្តន្ទាទោសឈ្មោះ [redacted] រាជ ដាក់ពន្ធនាគារកំណត់រយៈពេល ០២ (ពីរ) ឆ្នាំ ពីបទ ទទួលផលចោរកម្ម ប្រព្រឹត្តនៅចំណុចផ្លូវជាតិលេខ១ កែងផ្លូវលេខ៣៥១ ភូមិតាងៅ សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៩ ជាបទល្មើសដែលមានបញ្ញត្តិ និងផ្តន្ទាទោសតាមមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ។

៣. បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] រិទ្ធ ឈ្មោះ [redacted] វុទ្ធី ឈ្មោះ [redacted] វណ្ណនៈ ឈ្មោះ [redacted] ឧត្តម ឈ្មោះ [redacted] សុខឡេង និងឈ្មោះ [redacted] រាជ រួមគ្នាសងសំណងចំនួន ៨.០០០.០០០ (ប្រាំបីលាន) រៀល ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] សុផាន់ណា។

៤. បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] រិទ្ធ ឈ្មោះ [redacted] វុទ្ធី ឈ្មោះ [redacted] វណ្ណនៈ ឈ្មោះ [redacted] ឧត្តម ឈ្មោះ [redacted] សុខឡេង និងឈ្មោះ [redacted] រាជ រួមគ្នាសងសំណងចំនួន ៨.០០០.០០០ (ប្រាំបីលាន) រៀល ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] សែនដារ័ត្ន។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៩ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទទាំង ០៦ នាក់ និងដើមបណ្តឹងរដ្ឋប្បវេណីទាំង ០២ នាក់។ គូភាគីមានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់បានកំណត់។

**ក្រឡាបញ្ជីសវនាការ ចៅក្រមប្រឹក្សា ចៅក្រមប្រឹក្សា ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

ហត្ថលេខា និងត្រា [redacted]

---

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ០៣កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩

ក្រឡាបញ្ជី

[redacted]



Scanned with CamScanner